# លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្ម
# <u>ថ្នាក់ជាក្រុម</u>

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះរួមបញ្ចូលដោយភាគីរបស់វិទ្យាស្ថានបារាំងដែលមានទីតាំងនៅភ្នំពេញ(កម្ពុជា)មានឈ្មោះថា *"l'IFC"* និងភាគីម្ខាងទៀតគឺជាអ្នកដែលចង់ប្រើប្រាស់សេវាកម្មរបស់វិទ្យាស្ថានបារាំងមានឈ្មោះថា *"**អតិថិជន**"*។

## កម្មវត្ថុ

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះមានគោលបំណងកំណត់នូវកិច្ចសន្យារវាងវិទ្យាស្ថានបារាំងជាមួយអតិថិជននិងលក្ខខណ្ឌអនុវត្តចំពោះគ្រប់ការទិញឬប្រើប្រាស់សេវាកម្មរបស់វិទ្យាស្ថានបារាំងដែលអតិថិជនប្រើប្រាស់សំរាប់ការងារអាជីពឬការងារឯកជន។
ក្រុមការងាររបស់វិទ្យាស្ថានបារាំងផ្តល់សេវាកម្មគ្រប់បណ្តាញខ្លួននៅទូទាំងប្រទេស។
ការទទួលបានសេវាកម្មណាមួយពីវិទ្យាស្ថានបារាំងតម្រូវឱ្យអតិថិជនទទួលយកទាំងស្រុងនូវលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះ។
លក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មនេះគ្របដណ្តប់លើលក្ខខណ្ឌទូទៅដ៏ទៃទៀតឬលក្ខខណ្ឌដោយឡែកដែលមិនបានបង្ហាញតែបានទទួលស្គាល់ជាផ្លូវការដោយវិទ្យាស្ថានបារាំងនៅកម្ពុជា។
វិទ្យាស្ថានបារាំងនៅកម្ពុជារក្សាសិទ្ធកែប្រែលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្មរបស់ខ្លួនបានគ្រប់ពេល។ ក្នុងករណីនេះអតិថិជននឹងចុះហត្ថលេខាជាថ្មីនៅពេលចុះឈ្មោះម្តងទៀត។

តម្លៃសេវាកម្មដែលបង្ហាញនៅលើគេហទំព័ររបស់វិទ្យាស្ថានបារាំងជាតម្លៃដែលគិតជាដុល្លារអាមេរិកាំង។

## មាត្រា១ : និតិវិធីនិងលក្ខខណ្ឌទូទៅក្នុងការប្រើប្រាស់សេវាកម្មថ្នាក់ជាក្រុម

### ក ការចុះឈ្មោះ

អតិថិជនដែលមានបំណងចុះឈ្មោះជាមួយមជ្ឈមណ្ឌលភាសាចាំបាច់ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

### ក ការចុះឈ្មោះ
#### ការចុះឈ្មោះអនឡាញ

១ អ្នកអាចចុះឈ្មោះតាមគេហទំព័ររបស់យើងបានដោយចូល<u>ទៅកាន់ទំព័រ</u>ដែលពាក់ព័ន្ធនឹងថ្នាក់ជាក្រុម។
២ នៅលើទំព័រនោះ អ្នកគ្រាន់តែបំពេញពាក្យអនឡាញនោះជាមួយពិតមានចាំបាច់ ដូចជាគោត្តនាម នាម លេខទំនាក់ទំនង កម្រិតដែលចង់បាន ម៉ោងដែលចង់រៀន។ល។

៣ អតិថិជនត្រូវបង់ប្រាក់ភ្លាមៗនៅពេលចុះឈ្មោះតាមរយៈQR Code។
៤ បន្ទាប់ពីបានបង់ប្រាក់ហើយ អ្នកនឹងទទួលបានអ៊ីមែលដើម្បីបញ្ជាក់ពីការចុះឈ្មោះចប់ ហើយនឹងទទួលបានព៌តមានចាំបាច់សម្រាប់ចាប់ផ្តើមរៀន។

## ការចុះឈ្មោះដោយផ្ទាល់

ក អតិថិជនក៏អាចមកចុះឈ្មោះនៅទីតាំងផ្ទាល់បានដែរ។ ក្រុមការងារយើងខ្ញុំនឹងទទួលអ្នកដើម្បីផ្តល់ព៌តមានពិស្តារពាក់ព័ន្ធនិងថ្នាក់ជាក្រុមហើយនិងឆ្លើយរាល់សំណួររបស់អ្នកផងដែរ។
ខ អ្នកអាចបំពេញពាក្យចុះឈ្មោះជាក្រដាសនៅនិងកន្លែង ដោយបញ្ជាក់ពីតម្រូវការនិងក្តីរំពឹងរបស់អ្នកក្នុងការរៀននេះ (កម្រិត រៀនប៉ុន្មានថ្ងៃ រៀនម៉ោងណា។ល។)។
គ ការបង់ថ្លៃអាចធ្វើបាននៅនិងកន្លែងតាមរយៈQR Code តាមកាតធនាគារ តាមការផ្ទេរប្រាក់ឬក៏ទៅបង់លុយសុទ្ធនៅសាខាធនាការBREDតាមគណនីយដុល្លារ។
ឃ បន្ទាប់ពីបង់ថ្លៃរួច អ្នកនឹងទទួលបានបង្កាន់ដៃរួមទាំងកាលវិភាគសិក្សា។

ក្នុងករណីទាំងពីរ ក្រុមការងារនឹងនៅជួយសម្រួលនិងនាំផ្លូវអ្នកក្នុងការចុះឈ្មោះ។

វិទ្យាស្ថានតំរូវអោយធ្វើតេស្តវាស់ស្ទង់កំរិតភាសាសំរាប់អតិថិជនដែលធ្លាប់រៀននៅក្រៅវិទ្យាស្ថាន ឬនៅវិទ្យាស្ថានប៉ុន្តែបានផ្អាកការសិក្សាចាប់ពី២វគ្គជាប់ៗគ្នាឡើងទៅ។ ការធ្វើតេស្តវាស់ស្ទង់កំរិតមិនតម្រូវឲ្យបង់ថ្លៃទេហើយធ្វើតាមអនឡាញ។

បន្ទាប់ពីចុះឈ្មោះហើយភ្លាម អតិថិជននឹងទទួលបានគណនីយសិស្ស(Student portal) ឯកជនមួយភ្លាមដែលនៅទីនោះអតិថិជនអាចដឹងព័ត៌មានទាក់ទងនិងការសិក្សា ការទូទាត់ថ្លៃសិក្សារួមទាំងប្រវត្តិការសិក្សារបស់គាត់ (មេរៀន ការងារធ្វើនៅផ្ទះនិងលិខិតបញ្ជាក់ការសិក្សាដែរ)

## ខ បែបបទនៃថ្នាក់រៀនជាក្រុម

១ កំណាត់សម្គាល់ទូទៅ

ក្នុងករណីដែលវិទ្យាស្ថានលុបចោលការបង្រៀនណាមួយវិទ្យាស្ថាននឹងបង្រៀនសងវិញក្នុងពេលមួយសមស្រប ហើយវិទ្យាស្ថានសុំរក្សាសិទ្ធិក្នុងការកំណត់ថ្ងៃនិងពេលវេលានៃការបង្រៀនសងនេះ។

វិទ្យាស្ថានរក្សាសិទ្ធិក្នុងការបិទថ្នាក់រៀនប្រសិនបើចំនួនសិស្សចុះឈ្មោះមិនគ្រប់គ្រាន់។ ក្នុងករណីនេះ វិទ្យាស្ថាននឹងតម្កល់ប្រាក់របស់អតិថិជនសម្រាប់ចុះឈ្មោះរៀននៅវគ្គក្រោយ។ប្រសិនបើអតិថិជនចង់ដកប្រាក់ថ្លៃសិក្សាវិញ អតិថិជនត្រូវស្នើសុំនិងបំពេញពាក្យសុំដកប្រាក់វិញ។ ពាក់ព័ន្ធនិងការសុំព្យួរការសិក្សារឺសុំដកប្រាក់ថ្លៃសិក្សាសូមអានមាត្រាទី២។ ទឹកប្រាក់តម្កល់នេះមានសុពលភាព១២ខែគិតចាប់ពីថ្ងៃបង្កើត។

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

INSTITUT FRANÇAIS
Liberté
Créativité
Diversité

២ ការសុំព្យួរការសិក្សាដែលបណ្តាលមកពីអតិថិជន

គ្រប់ការសុំព្យួរការសិក្សាទាំងអស់ អតិថិជនត្រូវជូនដំណឹងជាលាយល័ក្ខអក្សរដោយសរសេរទៅកាន់ infocours@ifcambodge.com
វិទ្យាស្ថានរក្សាសិទ្ធិយល់ព្រមឬមិនយល់ព្រមតាមការសុំព្យួរការសិក្សានេះដែលមានសុពលភាពមួយឆ្នាំប្រសិនបើយើងខ្ញុំឯកភាព។

ក ការសុំព្យួរការសិក្សាដែលធ្វើឡើងដោយអតិថិជនបានបង់ប្រាក់រួច ហើយគាត់មិនបានមករៀនសោះ វិទ្យាស្ថាននឹងមិនធ្វើការផាកពិន័យថ្លៃសេវាឡើយ។
ខ ចំពោះការសុំព្យួរការសិក្សាដែលធ្វើឡើងក្នុងកំលុងពេល១សប្តាហ៍គិតចាប់ពីថ្ងៃចូលរៀន វិទ្យាស្ថាននឹងមិនធ្វើការផាកពិន័យថ្លៃសេវាឡើយ។
គ ផ្ទុយមកវិញប្រសិនបើវគ្គសិក្សាចាប់ផ្តើមលើស១សប្តាហ៍ហើយ ហើយអតិថិជនបានមករៀនសូម្បីតែម្តងគាត់មិនអាចសុំព្យួរបានទេ។

ម៉្យាងវិញទៀត:

1. ការបញ្ចុះតម្លៃផ្សេងដែលទទួលបានពេលចុះឈ្មោះចូលរៀននឹងត្រូវដកចេញវិញ។
2. ការពិន័យខាងលើនេះក៏ត្រូវអនុវត្តចំពោះអ្នកដែលមកចុះឈ្មោះក្រោយពេលចូលរៀនដូចគ្នា។
3. ក្នុងករណីមានការតំឡើងថ្លៃនៅវគ្គក្រោយទៀតនោះអតិថិជននឹងត្រូវបង់តម្លៃបន្ថែម។
4. អតិថិជនត្រូវបានអនុញ្ញាតិឲ្យផ្ទេរតម្លៃសិក្សាដែលព្យួរទៅមនុស្សផ្សេងទៀតបាន។ ក្នុងករណីនេះ អតិថិជនត្រូវមកស្នើសុំក្រុមការងារនៅកន្លែងចុះឈ្មោះ។

៣ លក្ខខណ្ឌដែលអាចឡើងថ្នាក់បាន

ផ្នែកគរុកោសល្យនឹងសម្រេចថាតើអតិថិជនអាចឡើងថ្នាក់បានឬមិនបានដោយឈរលើកត្តាបីដូចតទៅៈ
១ ការប្រឹងប្រែងរៀនសូត្រក្នុងថ្នាក់និងសមត្ថភាពភាសា
២ អត្រាវត្តមានក្នុងថ្នាក់
៣ លទ្ធផលប្រលងពេលកំពុងរៀន និងលទ្ធផលប្រលងបញ្ចប់វគ្គ។

ប្រសិនបើអតិថិជនមិនអាចមកប្រលងនៅថ្ងៃដែលកំណត់ គាត់អាចស្នើសុំចុះឈ្មោះប្រលងលើកទីពីរមកកាន់ក្រុមការងារ។ ប្រសិនបើយើងខ្ញុំឯកភាព គាត់អាចចុះឈ្មោះប្រលងដោយបង់ប្រាក់១០ដុល្លារ។
**ការធ្វើតេស្តតាមអនឡាញៈ** ក្នុងលក្ខខណ្ឌដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីអវត្តមាន (ឧទាហរណ៍ៈ សំបុត្រធ្វើដំណើរ)។ ជម្រើសនេះគឺសម្រាប់តែបេក្ខជនទាំងឡាយណា ដែលមានការលំបាកខ្លាំងផ្នែកភូមិសាស្ត្រនៅថ្ងៃប្រឡងផ្ទាល់តែប៉ុណ្ណោះ។

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

INSTITUT FRANÇAIS
Liberté
Créativité
Diversité

ប្រលងសញ្ញាបត្រDELFជាប់មិនមានន័យថាអ្នកអាចផ្លោះកម្រិត១ឬលើសនេះបានទេដើម្បីជៀសវាងការចន្លោះប្រហោងគ្រឹះភាសា។

៤ ការប្តូរក្រុម

រាល់ការសុំប្តូរថ្នាក់រៀន អតិថិជនត្រូវបំពេញពាក្យសុំហើយយកមកដាក់នៅកន្លែងចុះឈ្មោះឬក៏ផ្ញើមក infocours@ifcambodge.com ដោយភ្ជាប់មកជាមួយនូវលិខិតអះអាងផ្សេងៗ។ វិទ្យាស្ថានរក្សាសិទ្ធិបដិសេធការសុំប្តូរថ្នាក់។ ក្នុងករណីយើងឯកភាព ការសុំប្តូរនេះមានអស់ថ្លៃសេវាអ្វីទេ ក្នុងករណីមានកន្លែងទំនេរ។

៥ ការទទួលខុសត្រូវរបស់ឪពុកម្តាយចំពោះសិស្សកុមារ

ផ្នែកនេះទាក់ទងនឹងសិស្សដែលបានចុះឈ្មោះចូលរៀនថ្នាក់កុមារនិងវ័យជំទង់។

លក្ខ័ណ្ឌផ្សេងៗត្រូវបានបញ្ជាក់នៅក្នុងសំណុំឯកសារសម្រាប់ឪពុកម្តាយដែលត្រូវចុះហត្ថលេខានៅពេលចុះឈ្មោះចូលរៀន។
ឯកសារទាំងនេះមាននៅកន្លែងចុះឈ្មោះនៃមជ្ឈមណ្ឌលភាសា។

៦ កាលៈទេសៈពិសេស

ក្នុងកាលៈទេសៈពិសេសដែលនាំឲ្យមានការផ្អាកការបង្រៀនក្នុងថ្នាក់នៅមជ្ឈមណ្ឌលភាសា វិទ្យាស្ថានរក្សាសិទ្ធិរៀបចំការបង្រៀនតាមអនឡាញវិញតាមរយៈវីដេអូសន្និសិទក្នុងខណៈពេលបិទមជ្ឈមណ្ឌលភាសា។ ច្បាប់ពាក់ព័ន្ធនិងការព្យួរឬដកប្រាក់នៅតែដដែលដូចដែលបានចែងក្នុងឯកសារនេះស្រាប់។

## មាត្រា២ - តំលៃនិងបែបបទបង់ថ្លៃសិក្សាក្នុងថ្នាក់ជាក្រុម

### ក បែបបទនៃការបង់ប្រាក់សំរាប់វគ្គសិក្សា

ការចុះឈ្មោះនឹងចាត់ទុកជាផ្លូវការនៅពេលដែលអតិថិជនបានឯកភាពលើលក្ខខណ្ឌទូទៅនៃការផ្តល់សេវាកម្ម។ អតិថិជនត្រូវទូទាត់ថ្លៃសិក្សានៅពេលចុះឈ្មោះតាមរយៈការផ្ទេរប្រាក់ទៅធនាគារដែលជាដៃគូរបស់វិទ្យាស្ថាន តាមកាតធនាគារ ផ្ទេរពីធនាគារផ្សេងមកធនាគារយើងឬក៏ប្រើប្រាស់សេវាផ្ទេរលុយតាមទូរស័ព្ទជាលុយដុល្លារ។

RÉPUBLIQUE FRANÇAISE
Liberté
Égalité
Fraternité

INSTITUT FRANÇAIS Liberté Créativité Diversité

## ខ ការទិញសៀវភៅមេរៀន

1. មានតែអតិថិជនដែលបានចុះឈ្មោះចូលរៀនប៉ុណ្ណោះដែលអាចទិញសៀវភៅក្នុងតំលៃពិសេស ដោយគ្រាន់តែបង្ហាញវិក័យប័ត្រឬលិខិតអនុញ្ញាតឲ្យរៀនបានដែលយើងផ្តល់ឲ្យប៉ុណ្ណោះ។
2. អតិថិជនត្រូវតែមានសៀវភៅច្បាប់ដើមដែលត្រូវនឹងកម្រិតគាត់រៀន។
3. វិទ្យាស្ថានមិនអនុញ្ញាតិឱ្យប្រើសៀវភៅថតចម្លងក្នុងថ្នាក់រៀនទេ។វិទ្យាស្ថានរក្សាសិទ្ធិមិនទទួលអតិថិជនដែលគ្មានសៀវភៅច្បាប់ដើម លើកលែងតែឯកសារចម្លងដែលផ្តល់ដោយវិទ្យាស្ថាន។

## គ ការសងប្រាក់

ការចុះឈ្មោះចាត់ទុកថាជាផ្លូវការបន្ទាប់ពីចុះហត្ថលេខាលើឯកសារនេះ។ អតិថិជនត្រូវតែបំពេញពាក្យសុំដកប្រាក់ដោយភ្ជាប់ជាមួយនូវឯកសារបញ្ជាក់មូលហេតុច្បាស់លាស់រួចយកពាក្យនោះមកដាក់នៅផ្នែកទទួលចុះឈ្មោះចូលរៀនឬផ្ញើមកអាស័យដ្ឋានអីមែល infocours@ifcambodge.com ដោយយោងទៅតាមលក្ខខណ្ឌដូចខាងក្រោមនេះ៖

1. ក្នុងករណីវិទ្យាស្ថានបិទថ្នាក់សិក្សាណាមួយ ថ្លៃសិក្សាត្រូវបានតម្កល់ជាស្វ័យប្រវត្តិសម្រាប់អតិថិជនដែលមានសុពលភាពសម្រាប់មួយឆ្នាំដោយមិនគិតថ្លៃសេវាកម្មឡើយ។តែបើអតិថិជនចង់ដកប្រាក់វិញអតិថិជនត្រូវតែបំពេញពាក្យសុំដកប្រាក់។
2. ក្នុងករណីចាំបាច់ (ដូចជាអតិថិជន មានជំងឺធ្ងន់ធ្ងរ បាត់បង់ការងារ គ្រោះធម្មជាតិ មរណភាព ការចូលសំរាកពេទ្យ ការចាកចេញពីកម្ពុជាជារៀងរហូត) ថ្លៃសិក្សាត្រូវបានតម្កល់ជាស្វ័យប្រវត្តិដែលមានតម្លៃស្មើនិងថ្លៃម៉ោងដែលគាត់មិនទាន់បានរៀន ហើយមានសុពលភាពមួយឆ្នាំដោយមិនពិន័យថ្លៃសេវាកម្មឡើយ។បើអតិថិជនចង់ដកប្រាក់វិញអតិថិជនត្រូវតែបំពេញពាក្យសុំដកប្រាក់។
3. ក្រៅពីករណីទាំងពីរនេះ អតិថិជនមិនអាចសុំដកប្រាក់បានទេ។ សូមអានមេត្រា១ ខ២ សម្រាប់លក្ខខណ្ឌសុំព្យួរការសិក្សា។

ដោយស្វ័យប្រវត្តិ វិទ្យាស្ថាននឹងសងប្រាក់តាមធនាគារ សូមភ្ជាប់គណនីយធនាគារជាមួយពាក្យសុំ។ ថ្លៃទិញសម្ភារៈសិក្សាដូចជាសៀវភៅសិក្សាមិនអាចសងវិញបានទេ។

## ឃ ការបញ្ចុះតំលៃ

1. វិទ្យាស្ថានបញ្ចុះតំលៃ៥០%ចាប់ពីសមាជិកទី៣ក្នុងគ្រួសារតែ១ដែលបានចុះឈ្មោះរៀនដោយភ្ជាប់មកជាមួយនូវសៀវភៅគ្រួសារដើម្បីបញ្ជាក់។
ដើម្បីអាចទទួលបានការបញ្ចុះតម្លៃនេះពេលចុះឈ្មោះក្រោយទៀត អតិថិជនត្រូវមករៀនឲ្យបានយ៉ាងតិច៧០ភាគរយ។

RÉPUBLIQUE FRANÇAISE
*Liberté Égalité Fraternité*

INSTITUT FRANÇAIS — *Liberté Créativité Diversité*

2. វិទ្យាស្ថានបញ្ចុះតម្លៃ១០%សម្រាប់វគ្គបន្ទាប់ជូនចំពោះអតិថិជនចាស់ដែលបានរៀនចប់១វគ្គហើយបានចុះឈ្មោះវគ្គថ្មីដោយណែនាំអតិថិជនថ្មីម្នាក់ដែលមិនធ្លាប់បានរៀននៅវិទ្យាស្ថានបារាំងសោះឱ្យមកចុះឈ្មោះ។ ការបញ្ចុះតម្លៃ១០%នេះនឹងអាចទទួលបាននៅពេលចុះឈ្មោះវគ្គបន្ទាប់។
3. សិស្សដែលផ្អាកការសិក្សាលើសពី២៤ខែមិនអាចប្រើការបញ្ចុះតម្លៃនេះបានទេ។
4. ការបញ្ចុះតម្លៃទាំងពីរនេះមិនអាចបូកបញ្ចូលគ្នាបានទេ។
5. ជាចុងក្រោយ សិស្សដែលកំពុងរៀនអាចទទួលការបញ្ចុះតម្លៃ១៥ភាគរយសម្រាប់ការចុះឈ្មោះប្រលងសញ្ញាបត្រDELF/DALF ប្រសិនបើចំពេលតែមួយ។

### ង ការចុះឈ្មោះយឺត

ការពិន័យ៥ដុល្លារដែលជាថ្លៃសេវាកម្មនឹងត្រូវបានបូកបន្ថែមលើការបង់ថ្លៃសិក្សាចំពោះអតិថិជនដែលចុះឈ្មោះចូលរៀនក្រោយកាលបរិច្ឆេទដែលប្រកាសដោយវិទ្យាស្ថាន។

### ច បណ្ណាល័យ

អតិថិជនមានលទ្ធភាពប្រើប្រាស់សេវាកម្មបណ្ណាល័យពហុឯកសារដោយឥតគិតថ្លៃក្នុងរយៈពេល១ឆ្នាំបន្ទាប់ពីគាត់បានចុះឈ្មោះចូលរៀនហើយ។ គាត់ត្រូវបង្ហាញលិខិតបញ្ជាក់ថាជាសិស្ស។

ការចុះឈ្មោះនៅបណ្ណាល័យនេះអាចឲ្យអតិថិជនប្រើប្រាស់យ៉ាងពេញទំហឹងសេវារបស់ផ្នែកនេះដូចជាការខ្ចីឯកសារនិងមានសិទ្ធិចូលទៅកាន់បណ្ណាល័យអនឡាញ Culturethèque ថែមទៀតផង)។ សិស្សនិស្សិតត្រូវគោរពតាមបទបញ្ជាផ្ទៃក្នុងរបស់បណ្ណាល័យដែលចែងនៅលើ
https://www.ifcambodge.com/fr/mediatheque/

## មាត្រា៣ - កម្មសិទ្ធិបញ្ញា

ម៉ាក ឈ្មោះវិស័យ ផលិតផល កម្មវិធីកុំព្យូទ័រ រូបភាព វីដេអូ អត្ថបទ ឬគ្រប់ព័ត៌មាន គ្រប់ឯកសារទាំងអស់សុទ្ធសឹងជាកម្មសិទ្ធិបញ្ញាផ្តាច់មុខរបស់វិទ្យាស្ថានបារាំងតែមួយប៉ុណ្ណោះ។ រាល់ការចំលង ការកែប្រែ ការប្រើប្រាស់ ផ្នែកណាក៏ដោយដើម្បីហេតុផលអ្វីក៏ដោយ ត្រូវបានហាមឃាត់ជាដាច់ខាត។

ក្នុងក្របខ័ណ្ឌនៃការស្រាវជ្រាវសេវាអេឡិចត្រូនិចនៃសារព័ត៌មាននៅវិទ្យាស្ថានដែលបានផ្តល់ជូនអតិថិជនគ្មាននរណាម្នាក់មានសិទ្ធិយកទៅបង្កើតថ្មីធ្វើអាជីវកម្មផ្សព្វផ្សាយឬផ្សាយបន្តទោះជាមួយផ្នែកណាក៏ដោយនូវរាល់ឯកសារដូចជាកម្មវិធីកុំព្យូទ័រឬរូបភាពឬឯកសារសំលេងដែលវិទ្យាស្ថានបានដាក់ឱ្យប្រើប្រាស់។

## មាត្រា៤ - ច្បាប់ថតរូបនិងទិន្នន័យផ្ទាល់ខ្លួន

វិទ្យាស្ថានរក្សាសិទ្ធិសុំព័ត៌មានពីអតិថិជន។តាមរយៈការឯកភាពលើឯកសារនេះ អតិថិជនៈ

- អនុញ្ញាត្តិឲ្យវិទ្យាស្ថានប្រើប្រាស់ទិន្នន័យអតិថិជនដែលចុះឈ្មោះស្នើសុំទិដ្ឋាការ។
- អនុញ្ញាត្តិឲ្យវិទ្យាស្ថានផ្តល់ទិន្នន័យពេលអ្នកចុះឈ្មោះទៅធនាគារដៃគូABAដែលគោរពតាមច្បាប់រក្សាការសម្ងាត់ដោយធនាគារដើម្បីឲ្យអតិថិជនអាចប្រើប្រាស់សេវាផ្ទេរប្រាក់តាមទូរស័ព្ទដៃរបស់ABAបាន
- អនុញ្ញាត្តិឱ្យវិទ្យាស្ថានប្រើប្រាស់រូបភាពរបស់ខ្លួននៅតាមគេហទំព័រនិងតាមឯកសារផ្សព្វផ្សាយរបស់វិទ្យាស្ថានក្នុងក្របខ័ណ្ឌគរុកោសល្យតែប៉ុណ្ណោះ។

អតិថិជនមានសិទ្ធិចូលមើលនិងកែប្រែទិន្នន័យរបស់ខ្លួនផងដែរ។

- ដោយឯកភាពទិញក៏មានន័យថាអ្នកយល់ព្រមចុះក្នុងបញ្ជីអ្នកដែលយើងខ្ញុំនឹងផ្ញើសារព័តមានរបស់វិទ្យាស្ថានផងដែរប៉ុន្តែអ្នកក៏នៅមានលទ្ធភាពដកខ្លួនចេញពីបញ្ជីនេះវិញនៅពេលណាក៏បានតាមរយៈតំណរភ្ជាប់ដែលស្ថិតនៅក្នុងសារអេឡិចត្រូនិចនីមួយៗ។

## មាត្រា៥ - ករណីជម្លោះ

លក្ខខណ្ឌទូទៅនៃការផ្តល់សេវាត្រូវចំណុះក្រោមច្បាប់ក្នុងស្រុកនៃប្រទេសកម្ពុជា។
ក្នុងករណីមានជម្លោះណាមួយ គូវិវាទត្រូវដោះស្រាយចំពោះមុខច្បាប់ក្នុងស្រុក។